

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

## ប្រទេសកម្ពុជា

### ផ្តោតលើ៖ ឥទ្ធិពលនៃវិបត្តិស្បៀងអាហារ និង ប្រេងឥន្ធនៈសកលលោក លើតម្លៃស្បៀងអាហារ និងដំណើរការរបស់ផ្សារ

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខែមករា ឆ្នាំ២០២៣


**ការិយាល័យទីផ្សារកសិកម្ម (AMO)**
នាយកដ្ឋានផែនការនឹងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**
ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល
chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**រយៈពេល១ឆ្នាំនៃជម្លោះអ៊ុយក្រែន** សង្គ្រាម និងការដាក់ទណ្ឌកម្មលើរុស្ស៊ីនៅតែធ្វើឲ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យូម អ៊ាសូត ផូស្វ័រ) ហើយរុស្ស៊ី គឺជាប្រទេសដែលផលិត និងនាំចេញប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។

**សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO ក្នុងខែមករា ឆ្នាំ២០២៣ បន្តថយចុះ បន្ទាប់ពីបានឡើងខ្ពស់បំផុតក្នុងខែមីនា ឆ្នាំ២០២២។** វាទាបជាងខែធ្នូ ឆ្នាំ២០២២ បន្តិចគឺ -០,៨% និងទាបជាងខែដដែលកាលពីឆ្នាំមុន -៣,២% ដោយសារការធ្លាក់ចុះតម្លៃប្រេងឆា ទឹកដោះគោ និងស្ករ។

**វិបត្តិសេដ្ឋកិច្ចសកល** ជាមួយការព្យាករកំណើនប្រហែល ២,៩% ក្នុងឆ្នាំ២០២៣ ដែលទាបជាងមធ្យមភាគមុនការរាតត្បាតជំងឺកូវីដ-១៩ ទំនងជានឹងធ្វើឲ្យតម្រូវការថយចុះ ជាហេតុធ្វើឲ្យតម្លៃស្បៀងអាហារថយចុះ (ឧ. ថាមពល កសិកម្ម និងលោហៈ) ក្នុងឆ្នាំ២០២៣ និង២០២៤ ប៉ុន្តែនៅតែខ្ពស់ជាងប្រវត្តិតម្លៃក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។

**លទ្ធភាពទទួលបានជីកសិកម្ម មានភាពប្រសើរឡើងវិញ** ដោយសារតែតម្លៃជីបានថយចុះ ៤០% ធៀបនឹងដើមឆ្នាំ២០២២ជាពេលដែលតម្លៃឡើងខ្ពស់បំផុត តែនៅខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។ នេះទំនងជាធ្វើឲ្យតម្លៃធាតុចូលកសិកម្មមានការថយចុះ និងផលិតកម្មស្បៀងអាហារសកលមានភាពប្រសើរឡើង។ តម្លៃផលិតកម្មកសិកម្មសកលរំពឹងទុកថានឹងថយចុះ ៥,០% ក្នុងឆ្នាំ២០២៣ ប៉ុន្តែវានៅតែខ្ពស់ជាងពីមុន។ ការប្រែប្រួលអាកាសធាតុ និងភាពមិនច្បាស់លាស់នៃសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែនធ្វើឲ្យមានហានិភ័យនៃវិបត្តិតម្លៃស្បៀងអាហារ។

**វិបត្តិស្បៀងអាហារពិភពលោក ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរមួយផ្នែក ដោយការរឹតបន្តឹងពាណិជ្ជកម្មស្បៀងអាហារ**ដែលដាក់ដោយប្រទេសមួយចំនួនដើម្បីបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយតម្លៃ។ គិតត្រឹមថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ ប្រទេសចំនួន ២៣ បានជំរុញឱ្យមានការហាមឃាត់ការនាំចេញអាហារចំនួន ២៨ ហើយប្រទេសចំនួន ៦ បានអនុវត្តវិធានការកំណត់ការនាំចេញចំនួន ៥ ។

**បញ្ហានេះមិនបានកើតឡើងដាច់ដោយឡែកនោះទេ។** កូវីដ-១៩បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារ ជាហេតុធ្វើឲ្យមានឧបសគ្គដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល កើនឡើងអតិផរណា និងបំណុលក្នុងប្រទេសជាច្រើន-ធ្វើឲ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។ ភស្តុតាងចង្អុលបង្ហាញពីស្ថានភាពសន្តិសុខស្បៀងដែលមិនស្ថិតស្ថេរក្នុងចំណោមគ្រួសារកម្ពុជា ជាពិសេសសម្រាប់អ្នកដែលងាយរងគ្រោះបំផុតនិងអ្នកដែលរស់នៅក្នុងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់

**ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក កម្ពុជាជាប្រទេសប្រឈមខ្លាំងទៅនឹងការកើនឡើងតម្លៃថាមពល** ដោយសារតែការនាំចូលឥន្ធនៈខ្ពស់ធៀបនឹង GDP ការប្រើប្រាស់អគ្គិសនីក្នុងស្រុកនៅមានកម្រិត និងការពឹងលើឥន្ធនៈផូស៊ីល។ ជាការពិត ការឡើងថ្លៃប្រេង គួបផ្សំនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងចិនដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់កម្ពុជា ជាកត្តាសំខាន់រារាំងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ដែលបានព្យាករ ៥,២% សម្រាប់ឆ្នាំ២០២២ និង ៥,៦% សម្រាប់ឆ្នាំ២០២៣។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ** លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានា ក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) តាមដានតម្លៃលក់រាយ និងលក់ដុំ របស់ស្បៀងអាហារសំខាន់ៗ នៅក្នុងផ្សារចំនួន៥៦ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្ត្រ)។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួន ១.០០០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។

# មាតិកា


១. **របកគំហើញសំខាន់ៗ** ៣

២. **លទ្ធផល**

ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ ៤

ការទៅផ្សារ៖ទិន្នាការអតិថិជន ៥

ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៧

ថ្នាក់ជាតិ៖ ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ ៨

ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន ៩

ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ១០

ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ នឹងទីប្រជុំជន ១១

ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១២

ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១៣

៣. **បរិបទ**

ពាណិជ្ជកម្ម ១៤

ការឆ្លើយតបផ្នែកនយោបាយ ១៥

៤. **វិធីសាស្ត្រ និងទីតាំងផ្សារ** ១៦

៥. **ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៧

៦. **ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៨

៧. **ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៩

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

| ២០២២ | ២០២៣ |
|---|---|
| ៥,២% | ៥,៦%* |

**អតិផរណា**

| CPI ធ្នូ ២០២៣ | CPI មករា ២០២៣ |
|---|---|
| ១៩៧,៥ | ១៩៨,៨ |

*ផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជាក្នុងឆ្នាំ២០២២ គឺ ៥,២% ហើយព្យាករថានឹងកើន ៥,៦% ក្នុងឆ្នាំ២០២៣*។ ក្នុងខែមករា ឆ្នាំ២០២៣ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម (CPI) បានកើនឡើង ០,៧% ធៀបនឹងខែមុន និង៣,០% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ គ្រួសារកម្ពុជាចំណាយស្ទើរតែពាក់កណ្ដាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ (៦០% សម្រាប់គ្រួសារក្រីក្រ) (CSES ២០១៩/២០២០)។*

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)*




*ក្នុងខែមករា ឆ្នាំ២០២៣ __សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO(FFPI)__ បានធ្លាក់ដល់ ១៣១,២ (-០,៨% ធៀបនឹងខែមុន និង -៣,២% ធៀបនឹងខែដូចគ្នាក្នុងឆ្នាំមុន)។ **សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា (FPI)** ដែលជាផ្នែកមួយនៃ CPI របស់កម្ពុជា បានកើនឡើង ០,៥% ធៀបនឹងខែមុន ៣,៧% ធៀបនឹងខែដដែលកាលពីឆ្នាំមុន។*




***__តម្លៃប្រេងឥន្ធនៈនៅកម្ពុជា__មានការប្រែប្រួលតិចតួច ((±៥%) ក្នុងខែមករា ឆ្នាំ២០២៣ (MOC, ២០២៣)។***
*តម្លៃលក់រាយប្រេងសាំង (ធម្មតា) បានកើនឡើង ៣,៦% តែប្រហាក់ប្រហែលនឹងតម្លៃកាលពីឆ្នាំមុន (-០,២%)។ តម្លៃប្រេងម៉ាស៊ូតមានស្ថេរភាពបើធៀបនឹងខែមុន ប៉ុន្តែនៅតែខ្ពស់ជាងខែដដែលកាលពីឆ្នាំមុន (+១៥,១%) ហើយប្រហែលនៅតែមានឥទ្ធិពលអវិជ្ជមានលើផលិតកម្ម និងតម្លៃស្បៀង។*

# សង្ខេបរបកគំហើញសំខាន់ៗ

នៅក្នុងខែមករា ឆ្នាំ២០២៣ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP បន្ទាប់ពីឡើងដល់តម្លៃខ្ពស់បំផុតក្នុងខែតុលាបានបន្តធ្លាក់ចុះ ស្របពេលដែលតម្លៃស្បៀងអាហារ ជីកសិកម្ម និងប្រេងឥន្ធនៈលើសកលកំពុងធ្លាក់ចុះ។ តម្លៃកញ្ចប់ស្បៀងអាហារស្មើនឹង ២៥,៩ ដុល្លារ បានធ្លាក់ចុះ ២,៣% បើប្រៀបធៀបទៅនឹងខែមុន (MoM) ប៉ុន្តែនៅតែមានតម្លៃថ្លៃជាង ២,៩% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (YoY)។ តម្លៃម្ហូបអាហារបានធ្លាក់ចុះនៅក្នុងតំបន់ជនបទ ជាមួយនឹងតម្លៃមធ្យមនៃ BFB គឺ ២៥,២ ដុល្លារ (-២.២% MoM) ទាបជាងនៅក្នុងតំបន់ទីប្រជុំជនដែលតម្លៃស្មើនឹង ២៦,៥ ដុល្លារ (-១,៩% MoM)។

តម្លៃនៃទំនិញស្បៀងអាហារស្ទើរតែទាំងអស់នៅក្នុងកញ្ចប់មានស្ថេរភាព ឬបានធ្លាក់ចុះ ក្នុងខែមករា រួមមាន៖ ស៊ុតទា (-៥,៣% MoM), ត្រកួន (-១២,៤% MoM) សាច់ជ្រូក (-០,៧% MoM) និងប្រេងឆា (-៤,៧% MoM) លើកលែងតែអង្ករចម្រុះ (+១,៦% MoM) និងត្រីផ្ទក់ (+១,១% MoM)។ ការបន្ធូរបន្ថយតម្លៃស្បៀងអាចជាប់ទាក់ទងទៅនឹងការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈ និងធាតុចូលកសិកម្ម។ ការនាំចូលជីកសិកម្មផ្លូវការរបស់កម្ពុជាបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងខែមករា (២៧,៣% YoY)។ ជាលទ្ធផល តម្លៃស្បៀងអាហារភាគច្រើនមានកម្រិតប្រហាក់ប្រហែលកាលពីឆ្នាំមុន លើកលែងស៊ុតទា (+១៥,៤% YoY) និងត្រីផ្ទក់ (+១១,៦% YoY) ដែលនៅតែមានតម្លៃខ្ពស់។

បន្ទាប់ពីល្អប្រសើរខ្លាំងក្នុងខែវិច្ឆិកា ដំណើរការរបស់ផ្សារបានធ្លាក់ចុះបន្តិចទំនងដោយសារភាពមិនគួរឲ្យទុកចិត្តនៃស្ថិរភាពតម្លៃនិងការព្យាករតម្លៃ និងភាពខ្វះខាតនៃទំនិញចាំបាច់ ដោយសរតែមានការកើនឡើងនៃតម្រូវការអ្នកប្រើប្រាស់ក្នុងអំឡុងពេលថ្ងៃឈប់សម្រាកចូលឆ្នាំចិន និងការថយចុះតម្លៃប្រេងឥន្ធនៈ។

គិតត្រឹមខែមករា ឆ្នាំ២០២៣ ការបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចលើសពីផែនការថ្នាក់ជាតិ ដោយសារតែអំណោយផលនៃស្ថានភាពភ្លៀងធ្លាក់ និងទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រប។ ប៉ុន្តែ ប្រេងម៉ាស៊ូត ដែលជាប្រភពថាមពលដ៏សំខាន់ចំពោះផលិតកម្មកសិកម្ម និងជីកសិកម្ម នៅតែមានតម្លៃខ្ពស់ (+១៥,១% YoY)។

# ការដំណើរការរបស់ផ្សារ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ក្នុងខែមករា ឆ្នាំ២០២៣ ដំណើរការរបស់ផ្សារបានធ្លាក់ចុះបង្គួរ បើប្រៀបធៀបទៅនឹងខែមុន។ ការធ្លាក់ចុះនេះមកពីភាពមិនច្បាស់លាស់នៃស្ថិរភាពតម្លៃ និងការព្យាករតម្លៃ និងភាពអាចរកបានជាក់ស្តែងសម្រាប់ទំនិញសំខាន់ៗភាគច្រើន។ ប្រហែល ៣,៨% នៃប្រធានទីផ្សារ និងអ្នកលក់ដែលបានសម្ភាស បានរាយការណ៍ពីការកើនឡើងតម្លៃផ្គត់ផ្គង់នៅចុងខែមករា ធៀបនឹង ០,៥% នៅចុងខែធ្នូ ឆ្នាំ២០២២។




*[1]សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សាររួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។*

# ការទៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្ដាផ្សារទាំង៥៦ (ផ្សារចំនួន១១ ទើបបន្ថែមក្នុងខែកញ្ញា) ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្ដីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សាររបស់ពួកគាត់នៅសប្ដាហ៍ទី១ និងសប្ដាហ៍ទី៣ នៃខែនីមួយៗ។

ចំនួនអតិថិជនបានទៅផ្សារបានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងខែមករា ឆ្នាំ២០២៣ ដែលទំនងដោយសារតែការកើនឡើងនៃតម្រូវការរបស់អ្នកប្រើប្រាស់ក្នុងអំឡុងពេលប្រារព្ធពិធីចូលឆ្នាំចិននៅទូទាំងប្រទេស។




**បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ**

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងស៊េរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រក់បដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

ក្នុងខែមករា ឆ្នាំ២០២៣ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានធ្លាក់ចុះ ២,៣% ធៀបនឹងខែមុន (MoM) ដល់តម្លៃ ១០៦.៣៩៣ រៀល/ម្នាក់/ខែ (ប្រហែល ២៥,៩ ដុល្លារ) ប៉ុន្តែនៅតែខ្ពស់ជាងខែដដែលកាលពីឆ្នាំមុន ២,៩% (YoY)។ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានក៏បានធ្លាក់ចុះទាំងនៅជនបទ (២៥,២ដុល្លារ) និងទីប្រជុំជន (២៦,៥ ដុល្លារ)។




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃកញ្ចប់ស្បៀងអាហារខ្ពស់ជាងគេស្ថិតនៅផ្សារសាមគ្គី ក្នុងខេត្តកំពត គឺ ១៩១.០៧១ រៀល/ម្នាក់/ខែ (ប្រហែល ៣៩,១ ដុល្លារ) ដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ៣២,៦%។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារស្ទោង ក្នុងខេត្តកំពង់ធំ និងផ្សារឈើកាច់ ក្នុងខេត្តព្រៃវែង  គឺ ៩០.៧៩៣ រៀល/ម្នាក់/ខែ (ប្រហែល ២២,១ ដុល្លារ) ដែលទាបជាងតម្លៃមធ្យមថ្នាក់ជាតិ១៩,៧%។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់ស្បៀងអាហារបម្រែបម្រួលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ចាប់ពី៥% ឬខ្ពស់ជាង ឡើងទៅ គឺភាគច្រើនមាននៅផ្សារនៅទីប្រជុំជន ជាងនៅក្នុងផ្សារនៅជនបទ។

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែមករា ឆ្នាំ២០២៣)**




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ៤០,០% | ៦០,០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ២០,០% | ៨០,០% |
| < ៥% ខ្ពស់ជាង | ៣៦,៤% | ៦៣,៦% |
| < ៥% ទាបជាង | ៤៤,៤% | ៥៥,៦% |
| ៥% ទៅ ១០% ទាបជាង | ៦៦,៧% | ៣៣,៣% |
| ≥ ១០% ទាបជាង | ៣៣,៣% | ៦៦,៧% |

# ថ្នាក់ជាតិ៖ ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ

ប្រាក់ឈ្នួលពលកម្មសម្រាប់កម្មករក្នុងវិស័យកសិកម្ម និងសំណង់ត្រូវបានប្រមូលជារៀងរាល់ខែនៅទូទាំងប្រទេសដោយ AMO។ ក្នុងខែមករា ឆ្នាំ២០២៣ តម្លៃមធ្យមថ្នាក់ជាតិប្រាក់ឈ្នួលពលកម្មបានធ្លាក់ចុះដល់ ៣២.៦៣៣ រៀលក្នុងមួយថ្ងៃ (ប្រហែល ៨,១០ ដុល្លារ -៦,៨% ធៀបខែមុន និង -៩,០% ធៀបខែដដែលកាលពីឆ្នាំមុន)។

កម្លាំងទិញស្បៀងអាហារ (ToT) ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្លាំងទិញស្បៀងអាហាររបស់គ្រួសារ ហើយត្រូវបានវាស់វែងដោយប្រើផលធៀបរវាងអត្រាប្រាក់ឈ្នួលកម្មករគ្មានជំនាញ និងតម្លៃមធ្យមលក់រាយអង្ករចម្រុះ។ វាបង្ហាញពីបរិមាណអង្ករ ដែលកម្មករគ្មានជំនាញអាចទិញដោយប្រើប្រាស់ប្រាក់ឈ្នួលក្នុងមួយថ្ងៃរបស់គាត់។ ក្នុងខែមករា ឆ្នាំ ២០២៣ ToT ក៏បានធ្លាក់ចុះដល់ ១៥,៦ គីឡូក្រាមក្នុងមួយថ្ងៃ ដែលទាបជាងខែមុន ៨,២% និងទាបជាងខែដូចគ្នាកាលពីឆ្នាំមុន ៧,២% ដែលបង្ហាញពីកម្លាំងទិញស្បៀងអាហារទាបរបស់ប្រជាជនងាយរងគ្រោះ ដោយសារតែការថយចុះនៃប្រាក់ឈ្នួលពលកម្ម។

### ប្រាក់ឈ្នួលពលកម្ម (ខែមករា ឆ្នាំ២០២៣)




### កម្លាំងទិញស្បៀងអាហារ (ខែមករា ឆ្នាំ២០២៣)



# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែមករា ឆ្នាំ២០២៣ តម្លៃស៊ុតទា និងតម្លៃត្រកួន បានធ្លាក់ចុះ ខណៈតម្លៃអង្ករចម្រុះបានកើនឡើងបន្តិច បើធៀបនឹងខែមុន។ តម្លៃស៊ុតទាបានបន្តធ្លាក់ចុះ ៥,៣% ធៀបនឹងខែមុន ដែលទំនងដោយសារការធ្លាក់ចុះនៃតម្លៃចំណីទា (ភាគច្រើនស្រូវ) និងការប្រកួតប្រជែងតម្លៃនៃទំនិញសម្បូរប្រូតេអ៊ីនផ្សេងទៀតដូចជាត្រី និងសាច់ជ្រូក។ ប៉ុន្តែ តម្លៃស៊ុតទានៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ១៥,៥%។ តម្លៃត្រកួនបានថយចុះចំនួន ១២,៤% ធៀបនឹងខែមុន ប៉ុន្តែនៅតែមានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ៣,០%។ តម្លៃអង្ករចម្រុះបានកើនឡើងបន្តិចគឺ ១,៦% ធៀបនឹងខែមុន និង ៣,៤% ធៀបនឹងឆ្នាំមុន)។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។
[2]តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែមករា ឆ្នាំ២០២៣ តម្លៃត្រីផ្ទក់បានកើនឡើងបន្តិច (+១,១%) ប៉ុន្តែតម្លៃសាច់ជ្រូក (-០,៧%) និងប្រេងឆា (-៤,៧%) បន្តនិន្នាការថយចុះ។ តម្លៃប្រេងឆាទាបជាងកាលពីឆ្នាំមុនចំនួន ៣,៦% ហើយតម្លៃសាច់ជ្រូកទាបជាងកាលឆ្នាំមុនចំនួន ១០,៤%។ ទោះយ៉ាងណា ត្រីផ្ទក់នៅតែមានតម្លៃខ្ពស់ជាងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (+១១,៦%)។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




[1]តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅក្នុងខែមករា ឆ្នាំ២០២៣ ស្បៀងអាហារសំខាន់ៗភាគច្រើនក្នុងចំណោមសរុបទាំងអស់៧មុខ ដែលបានកំពុងតាមដាន នៅទីប្រជុំជនមានតម្លៃមធ្យមលក់រាយខ្ពស់ជាងនៅជនបទ លើកលែងអង្ករចម្រុះ និងប្រេងឆា (តារាង១)។

តម្លៃមធ្យមលក់រាយអង្ករចម្រុះ ត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា មានបម្រែបម្រួលតិចតួច (< ៥,០%) និងមានទិសដៅបម្រែបម្រួលដូចគ្នា (លើកលែងតែសាច់ជ្រូក) ទាំងនៅទីប្រជុំជន និងទីជនបទ បើធៀបនឹងខែមុន។ តម្លៃស៊ុតទា បានថយចុះ ៦,១% នៅជនបទ និង ៤,៧% នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃត្រកួនបានថយចុះ ១៣,១% នៅជនបទ និង ១០,៦% នៅទីប្រជុំជន បើធៀបនឹងខែមុន។ តម្លៃដំឡូងផ្កាពណ៌លឿងបានកើនឡើងគួរឲ្យកត់សម្គាល់ទាំងនៅជនបទ (២៣,២%) និងនៅទីប្រជុំជន (២១,០%)។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.០៧១ | ២.១១៥ |
| ត្រីផ្ទក់ (រស់) (គក) | ១០.៩២៣ | ១០.៥៩៨ |
| សាច់ជ្រូក (គក) | ១៦.៩៩៩ | ១៥.៧៥៧ |
| ស៊ុតទា (១០គ្រាប់) | ៥.៣៩៩ | ៥.៣៣៧ |
| ប្រេងឆា (៥លីត្រ) | ២៩.៦៧៩ | ២៩.៩៨៧ |
| ត្រកួន (គក) | ៣.៣៧៨ | ២.៩៣០ |
| ដំឡូងផ្កាពណ៌លឿង | ៣.២៨៨ | ២.៨១៣ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែធ្នូ ឆ្នាំ២០២២ និងខែមករា ឆ្នាំ២០២៣




[1] ទិន្នន័យនេះទទួលបានពីផ្សារចំនួន៥៦។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។

[2] តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបចាប់ពីខែវិច្ឆិកា ឆ្នាំ២០២២ ដល់ខែមករា ឆ្នាំ២០២៣ មានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ទោះជាយ៉ាងណា សរុបទឹកភ្លៀងធ្លាក់ក្នុងខែមករា មានរបាយមិនទៀងទាត់ និងមិនស្មើគ្នានៅទូទាំងប្រទេស (ផែនទីខាងក្រោមខាងស្តាំ) ដែលភាគពាយ័ព្យប្រទេសទទួលបានទឹកភ្លៀងទាបជាងកម្រិតធម្មតាបន្តិច។

យោងតាមព័ត៌មានព្យាករណ៍តាមរដូវកាលរបស់ IRI Columbia University ខេត្តនៅភាគអាគ្នេយ៍ និងភាគឦសានប្រទេស ដូចជា ខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ ព្រៃវែង និងស្វាយរៀង ត្រូវបានរំពឹងថានឹងទទួលបានទឹកភ្លៀងលើសពីកម្រិតធម្មតាបន្តិចក្នុងកំឡុងរយៈពេល៣ខែខាងមុខចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២៣។ លក្ខខណ្ឌនេះនឹងបន្តអំណោយផលសម្រាប់ការដាំដុះស្រូវរដូវប្រាំង។ ទោះជាយ៉ាងណាក៏ដោយ ភ្លៀងធ្លាក់ច្រើនលើសលុប បណ្តាលឲ្យជាំទឹក អាចប៉ះពាល់ជាអវិជ្ជមានដល់ដំណាំ និងធ្វើឱ្យបាត់បង់ទិន្នផល។ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានព្យាករថា រដូវវស្សា ឆ្នាំ២០២៣ នឹងចាប់ផ្តើមនៅក្នុងសប្តាហ៍ទី១ ខែឧសភា នៅតំបន់ទំនាបកណ្តាល និងតំបន់ឆ្នេរសមុទ្រ និងនៅពាក់កណ្តាលខែឧសភា នៅផ្នែកដទៃទៀតនៃប្រទេស។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (គិតត្រឹមខែមករា ឆ្នាំ២០២៣) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | | ប្រមូលផល | | | | | | | | រៀបចំដី និង សាបព្រោះ | |
| ស្រូវរដូវវស្សារ | ប្រមូលផល | | | | រៀបចំដី និង សាបព្រោះ | | ស្ទូង / ដាំដុះ | | | | ប្រមូលផល | |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែមករា ឆ្នាំ២០២៣




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

បរិមាណទឹកភ្លៀងខ្ពស់ជាងធម្មតាអំណោយផលសម្រាប់រុក្ខជាតិ នៅក្នុងខែមករា ឆ្នាំ២០២៣។ ស្ថានភាពរុក្ខជាតិដែលមានសុខភាពល្អគ្រប់ដណ្តប់នៅទូទាំងប្រទេស ជាពិសេស តំបន់ជុំវិញបឹងទន្លេសាប និងតំបន់ទំនាបកណ្តាល ជាតំបន់ដែលដាំដុះស្រូវរដូវប្រាំងច្រើន។ ផ្ទុយមកវិញ ស្ថានភាពរុក្ខជាតិដែលមានសុខភាពទាបជាងធម្មតាត្រូវបានអង្កេតឃើញនៅតំបន់ភាគខាងជើងប្រទេស។

ការប្រមូលផលស្រូវរដូវវស្សានៅតែបន្តក្នុងខែមករា ឆ្នាំ២០២៣។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ ដំណាំស្រូវរដូវវស្សាបានប្រមូលផលរួចរាល់ជិត ៨៣% នៃផ្ទៃដីដាំដុះសរុប (ប្រហែល ២,៣ លានហិកតា) ហើយទទួលបានផលិតផលស្រូវ ស្មើនឹង ៧,៦ លានតោន។ គិតត្រឹមខែមករា ឆ្នាំ២០២៣ ការដាំដុះស្រូវរដូវប្រាំងសម្រេចបានប្រមាណ ៦០៩.៨៣៩ ហិកតា ស្មើនឹង ១២៣% នៃផែនការជាតិប្រចាំឆ្នាំ នេះបើយោងតាមក្រសួងធនធានទឹក និងឧតុនិយម (MoWRAM)។ តួលេខនេះត្រូវបានរាយការណ៍ថាខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុនចំនួន ៦,០%។

ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)
ក្នុងខែមករា ឆ្នាំ២០២៣




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*
*ចំណាំ៖ ការបកស្រាយពីស្ថានភាពរុក្ខជាតិមានកម្រិតសម្រាប់តំបន់គ្របដណ្តប់ដោយពពកឬមិនមានទន្និន័យ*

# ពាណិជ្ជកម្ម

ស្ថិតិសរុបនៃពាណិជ្ជកម្មក្នុងខែដំបូងឆ្នាំ២០២៣ ទាបជាងខែដដែលកាលពីឆ្នាំមុន។ ក្នុងខែមករា ឆ្នាំ២០២៣ ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ 1.៥៦៧,៩ លានដុល្លារ ដែលទាបជាងរយៈពេលដដែលកាលពីឆ្នាំមុនប្រមាណ ១៣,៩%។ ក្នុងខែមករា ឆ្នាំ២០២៣ ការនាំចេញអង្ករមានចំនួន ៣៦.៩០០ តោន (មានតម្លៃស្មើ ២៨,៨៣ លានដុល្លារ) បានថយចុះ ៣០,៤% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន ដោយសារតែការពន្យាពេលការដឹកជញ្ជូនទៅកាន់ប្រទេសចិនកំឡុងពេលចូលឆ្នាំចិន (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០២៣)។ បន្ថែមលើការនាំចេញអង្ករ ការនាំចេញស្រូវមានចំនួន ២៥២.៧១៤ តោន (មានតម្លៃ ៦៣,១៧ លានដុល្លារ) ក្នុងរយៈពេលដូចគ្នា (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣)។ សហព័ន្ធស្រូវអង្ករកម្ពុជា (CRF) បានសន្យាថានឹងជម្រុញការនាំចេញអង្ករឲ្យបាន ៧៥០.០០០ តោន ក្នុងឆ្នាំ២០២៣នេះ និង ១ លានតោន ក្នុងឆ្នាំ២០២៥ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០២៣)។

នៅក្នុងខែមករា ឆ្នាំ២០២៣ ប្រទេសកម្ពុជាបាននាំចូលជាផ្លូវការសរុបមានតម្លៃ ៩៦,៨ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៤,៣ លានដុល្លារ (-៩១,៧% ធៀបឆ្នាំមុន) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុងដែលអាចបរិភោគបានបន្លែដែលអាចបរិភោគបាន ឬស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ៩២,៥ លានដុល្លារ (+២,៩%)។ ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ១៨,៣ លានដុល្លារ (+២៧,៣% ធៀបឆ្នាំមុន) ក្នុងខែមករា ឆ្នាំ២០២៣។

ខេត្តភាគពាយ័ព្យប្រទេស ដូចជា ខេត្តបាត់ដំបង ពោធិសាត់ ប៉ៃលិន និងខេត្តបន្ទាយមានជ័យត្រូវបានដាក់ស្នើជាតំបន់ប៉ូលសេដ្ឋកិច្ចទីបួន ដែលឲ្យឈ្មោះថា "ច្រករបៀងត្រី និងស្រូវ" ដើម្បីអំពាវនាវរកការអភិវឌ្ឍ និងការវិនិយោគដ៏មានសក្តានុពលបន្ថែម (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២៣)។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ខែមករា ឆ្នាំ២០២៣




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២៣*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ គ្រួសារក្រីក្រប្រមាណ <u>៧០៦.៦៩៨ គ្រួសារ</u> (ប្រមាណ ២,៧៨ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៩៣១,៧១ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣។ កម្មវិធីនេះនឹងបន្តក្នុងឆ្នាំ២០២៣ <u>ដោយមានថវិកាបម្រុងចំនួន ៨០០ លានដុល្លារ ហើយកម្មវិធីជំនួយសាច់ប្រាក់ដល់គ្រួសារងាយរងគ្រោះ (គ្រួសារដែលមានជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ជាមួយថវិកាបម្រុងចំនួន ៦៥ លានដុល្លារ។</u>

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចែក<u>**គ្រាប់ពូជស្រូវចំនួន ៦.៧១២,២៥ តោន**</u> ដែលស្ថិតនៅក្រោមប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដល់គ្រួសារដែលបានរងគ្រោះដោយទឹកជំនន់នៅក្នុងខេត្តចំនួន២២ ។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

ក្រោមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១ - ២០២៣ របស់រដ្ឋាភិបាល ប្រាក់កម្ចីចំនួន <u>៩២.៩៧ លានដុល្លារ</u> ត្រូវបានផ្តល់សម្រាប់ការស្តារ និងលើកកម្ពស់វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣។

ក្នុងឆ្នាំ២០២៣ រដ្ឋាភិបាលបានរាយការណ៍ថា ព្រឹត្តិការណ៍ ២សំខាន់ៗ គឺអង្គរសង្រ្កាន ក្នុងខែមេសា និងការប្រកួតកីឡាស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម ក្នុងខែឧសភា និងខែមិថុនា នឹងទាក់ទាញ<u>ភ្ញៀវទេសចរអន្តរជាតិប្រមាណ ៣-៤ លាននាក់</u> មកទស្សនាកម្ពុជា។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាម<u>ក្រសួងសុខាភិបាល</u> គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ ពលរដ្ឋអាយុលើសពី៣ឆ្នាំ ជាង ១៦,២៦ លាននាក់ (៥០,៥% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងតិចដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៤,២% (៩៥,២៦% នៃប្រជាជនសរុប)។

<u>ប្រទេសកម្ពុជា បានពង្រឹងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩</u> ដើម្បីធានាដល់ប្រជាពលរដ្ឋ ទទួលបានកម្រិតមូលដ្ឋាន និងដូសជម្រុញ ខណៈករណីកូវីដ-១៩ កំពុងកើនឡើងទាំងក្នុងប្រទេស និងក្នុងតំបន់។




*ប្រភព៖ <u>ទំព័រហ្វេសប៊ុកផ្លូវការរបស់គាំពារសង្គមកម្ពុជា ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២</u>*




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,089 | → 1.6% | → -1.1% | → 3.4% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 10,771 | → 1.1% | → 3.7% | ↑ 11.6% |
| ២.២ ត្រីប្រា(រស់) | Kg | 6,831 | → 0.9% | → -3.1% | ↑ 9.8% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 7,645 | → 1.5% | ↓ -8.3% | → -0.8% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 26,274 | → 0.9% | → 2.2% | ↑ 6.6% |
| ២.៥ ប្រហុក | Kg | 8,974 | ↓ -7.7% | ↓ -14.8% | ● |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 16,405 | → -0.7% | ↓ -8.9% | ↓ -10.4% |
| ៣.២ សាច់គោឃារ | Kg | 19,521 | → -2.5% | → 4.1% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 14,195 | ↑ 5.9% | ↑ 11.6% | ● |
| ៤.១ ស៊ុតទា | 10 eggs | 5,368 | ↓ -5.3% | ↓ -11.8% | ↑ 15.4% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,944 | → -2.0% | ↓ -6.1% | ↑ 7.4% |
| ៥.១ ប្រេងឆា | 5 litres | 29,813 | → -4.7% | ↓ -6.8% | → -3.6% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,334 | ↑ 6.3% | → 1.9% | ↑ 9.2% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,383 | → 0.8% | → 0.9% | ● |
| ៧.១ សណ្តែកដី* | Kg | 9,958 | → -2.5% | → 0.3% | ↑ 7.5% |
| ៧.២ សណ្តែកសៀង | Kg | 5,380 | → -3.6% | → 0.2% | ● |
| ៧.៣ សណ្តែកខៀវ | Kg | 5,918 | → -1.4% | → -0.1% | ● |
| ៨.១ ត្រកួន | Kg | 3,191 | ↓ -12.4% | ↓ -31.2% | → 3.0% |
| ៨.២ ការ៉ុត* | Kg | 3,496 | → -0.2% | → -2.6% | ↓ -8.6% |
| ៨.៣ ស្លឹកបាស* | Kg | 4,995 | ↓ -16.3% | → -3.1% | → -0.6% |
| ៨.៤ ស្លឹកម្រុំ* | Kg | 5,077 | ↓ -17.8% | ↓ -5.9% | → 1.5% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 3,503 | ↓ -29.2% | ↓ -45.2% | → -2.7% |
| ៨.៦ ស្ពៃតឿ* | Kg | 3,403 | ↓ -29.0% | ↓ -40.1% | → 4.2% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 2,958 | ↓ -35.6% | ↓ -41.2% | → -0.4% |
| ៨.៨ ស្ពៃខៀវ* | Kg | 3,177 | ↓ -26.9% | ↓ -32.9% | → -1.7% |
| ៨.៩ ផ្ទីដូង* | Kg | 4,281 | ↓ -12.8% | ↓ -24.1% | → 3.9% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 5,272 | ↓ -23.2% | ↑ 27.0% | ↓ -21.9% |
| ៨.១១ ត្រយលៅ្ត* | Kg | 4,799 | ↓ -15.5% | ↑ 17.6% | ↑ 28.0% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,883 | ↓ -8.3% | → -2.7% | ↑ 9.4% |
| ៨.១៣ ឃ្លោក* | Kg | | ● | ● | ● |
| ៨.១៤ ត្រឡាច | Kg | 2,283 | ↓ -34.2% | ↓ -33.7% | ↓ -27.0% |
| ៨.១៥ ត្រប់វែង | Kg | 3,778 | ↓ -18.5% | → -0.6% | ↑ 17.6% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,710 | ↓ -21.9% | → -2.9% | → 3.3% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,319 | → -0.5% | ↓ -18.3% | ↓ -9.7% |
| ៨.១៨ ននោងមូល | Kg | 3,013 | ↓ -14.8% | ↓ -18.8% | → 2.2% |
| ៨.១៩ ននោងជ្រុង* | Kg | 3,019 | ↓ -19.9% | ↓ -18.5% | ↓ -5.2% |
| ៨.២០ ល្ពុងខ្ទី* | Kg | 1,702 | ↑ 9.1% | ↑ 20.0% | ↑ 19.5% |
| ៨.២១ សណ្តែកកួរ | Kg | 3,804 | ↓ -29.9% | ↓ -10.2% | ↓ -38.3% |
| ៨.២២ ត្រយូងចេក* | Kg | 2,256 | → -1.1% | → 1.5% | ↓ -18.6% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 5,651 | ↓ -25.1% | ↓ -42.4% | → -0.8% |
| ៨.២៤ ដើមខាត់ណា* | Kg | 4,568 | ↓ -30.2% | ↓ -36.7% | → -0.6% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 3,152 | ↑ 24.7% | ↑ 24.3% | ↑ 30.6% |
| ៨.២៦ ខ្ទឹមសរ | Kg | 5,153 | → 2.4% | → -3.1% | ● |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 4,113 | → -2.3% | ↓ -7.7% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,156 | → -2.5% | → 3.2% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 3,167 | ● | ↓ -36.7% | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,648 | → 3.2% | → -1.5% | ● |
| ១១.១ កូកាកូឡា | 330 ml | 1,988 | → 2.4% | → 2.6% | ● |
| ៧.១ សាំងធម្មតា | litre | 4,232 | → -0.1% | → -3.4% | ● |
| ៧.២ ម៉ាស៊ូត | litre | 4,526 | → -1.9% | ↓ -7.7% | ● |
| ៨.១ ជីអ៊ុយរ៉េ | Kg | 3,500 | → -2.8% | ↓ -9.1% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%

→ ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%

↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%

● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 1,940 | → 1.5% | → -0.7% | → 3.6% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 9,807 | → 1.5% | ↑ 5.8% | ↑ 13.2% |
| ២.២ ត្រីប្រា(រស់) | Kg | 6,091 | → -0.8% | → -1.7% | ↑ 7.7% |
| ២.៣ ត្រីអណ្ដែង(រស់) | Kg | 6,888 | → 1.9% | ↓ -6.9% | → -1.4% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 24,244 | → 1.3% | → 3.2% | ↑ 7.7% |
| ២.៥ ប្រហុក | Kg | 7,920 | ↓ -7.8% | ↓ -15.3% | • |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 14,999 | → -1.2% | ↓ -9.6% | ↓ -10.9% |
| ៣.២ សាច់គោឃារ | Kg | 17,772 | → -1.7% | → 3.7% | • |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 13,107 | ↑ 5.3% | ↑ 15.4% | • |
| ៤.១ ស៊ុតទា | 10 eggs | 4,872 | ↓ -6.3% | ↓ -13.0% | ↑ 16.5% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,416 | → -4.3% | ↓ -6.4% | ↑ 8.3% |
| ៥.១ ប្រេងឆា | 5 litres | 28,823 | → -4.5% | ↓ -6.7% | → -4.2% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,096 | ↑ 7.9% | ↑ 9.1% | ↑ 9.8% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,023 | → 1.6% | → 1.3% | • |
| ៧.១ សណ្ដែកដី* | Kg | 9,228 | → 0.9% | → 3.6% | ↑ 8.0% |
| ៧.២ សណ្ដែកសៀង | Kg | 5,026 | → -1.7% | → 2.7% | • |
| ៧.៣ សណ្ដែកខៀវ | Kg | 5,429 | → -1.3% | → 1.2% | • |
| ៨.១ ត្រកួន | Kg | 2,675 | ↓ -18.7% | ↓ -32.5% | ↑ 5.9% |
| ៨.២ ការ៉ុត* | Kg | 2,916 | → 2.4% | → -2.3% | ↓ -6.7% |
| ៨.៣ ស្ពៃក្ដោបបាស* | Kg | 4,033 | ↓ -13.7% | → -0.4% | → -4.9% |
| ៨.៤ ស្ពៃក្ដោបម្រំ* | Kg | 3,932 | ↓ -20.8% | ↓ -7.1% | ↓ -15.2% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 2,815 | ↓ -33.6% | ↓ -48.4% | → -2.6% |
| ៨.៦ ម្ទេសតឿ* | Kg | 2,704 | ↓ -32.9% | ↓ -43.3% | ↑ 5.4% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 2,320 | ↓ -39.6% | ↓ -45.0% | → -2.3% |
| ៨.៨ ម្ទេសខៀវ* | Kg | 2,450 | ↓ -32.3% | ↓ -37.5% | → -5.0% |
| ៨.៩ ផ្ទីដូង* | Kg | 3,300 | ↓ -14.2% | ↓ -26.4% | → -1.4% |
| ៨.១០ ស្ពៃកងប់* | Kg | 4,148 | ↓ -23.5% | ↑ 19.9% | ↓ -37.0% |
| ៨.១១ ត្រយស្ដៅ* | Kg | 3,713 | ↓ -11.9% | ↑ 10.3% | ↑ 11.4% |
| ៨.១២ ផ្កាស្ដៅ* | Kg | 2,398 | ↓ -6.7% | → 1.1% | ↑ 13.8% |
| ៨.១៣ ឃ្លោក* | Kg | | • | • | • |
| ៨.១៤ ត្រឡាច | Kg | 1,787 | ↓ -36.3% | ↓ -36.7% | ↓ -33.0% |
| ៨.១៥ ត្រប់វែង | Kg | 3,116 | ↓ -20.6% | → 1.1% | ↑ 16.1% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,097 | ↓ -24.0% | → -0.5% | → 1.6% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 3,665 | → 1.0% | ↓ -18.3% | ↓ -8.2% |
| ៨.១៨ ននោងមូល | Kg | 2,333 | ↓ -18.4% | ↓ -20.1% | ↓ -8.8% |
| ៨.១៩ ននោងជ្រុង* | Kg | 2,322 | ↓ -24.9% | ↓ -21.6% | ↓ -17.7% |
| ៨.២០ ល្ពៅងខ្ចី* | Kg | 1,325 | ↑ 16.3% | ↑ 30.8% | ↑ 25.5% |
| ៨.២១ សណ្ដែកគួរ | Kg | 3,200 | ↓ -30.7% | ↓ -6.8% | ↓ -42.1% |
| ៨.២២ ត្រយូងចេក* | Kg | 1,836 | → 2.9% | ↑ 6.3% | ↓ -21.8% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 4,900 | ↓ -24.6% | ↓ -42.3% | → -0.7% |
| ៨.២៤ ដើមខាត់ណា* | Kg | 3,843 | ↓ -32.1% | ↓ -38.9% | → -0.4% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,598 | ↑ 27.8% | ↑ 28.8% | ↑ 35.5% |
| ៨.២៦ ខ្ទឹមសរ | Kg | 4,582 | → 4.1% | → -0.9% | • |
| ៨.២៧ អំពិលទុំ | Kg | 3,570 | → 1.0% | ↓ -5.9% | • |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,756 | → 0.3% | ↑ 10.8% | • |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 2,733 | • | ↓ -39.3% | • |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,497 | ↑ 7.0% | → 2.8% | • |
| ១១.១ កូកាកូឡា | 330 ml | 1,577 | → -1.1% | → -2.3% | • |
| ៧.១ សាំងធម្មតា | litre | 4,056 | → -1.8% | → -4.5% | • |
| ៧.២ ម៉ាស៊ូត | litre | 4,419 | → -2.8% | ↓ -8.5% | • |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,050 | → -4.4% | ↓ -10.7% | • |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

* *តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលើតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឲ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 26,237 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.8 | 29,824 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 16.4 | 20,311 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 8.6 | 3,095 |
| Diary | Milk | ---NA--- | 7 | 12.0 | - | - |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 6.6 | 2,557 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.2 | 22,490 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 3.2 | 1,880 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | - | - |
| Fruit | Banana | ---NA--- | 91 | 96.4 | - | - |
| | | **Total** | **1,937** | **950.6** | - | **106,393** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឲ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ ខែមករា ឆ្នាំ២០២៣ WFP ប្រចាំប្រទេសកម្ពុជា។*